# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងរ៉ែ និងថាមពល

## អគ្គិសនីកម្ពុជា

# គម្រោងអន្តរកាលថាមពលប្រកប ដោយនិរន្តរភាពនៅកម្ពុជា (P510217)

# ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

(សេចក្តីព្រាង)

ថ្ងៃទី07 ខែមករា ឆ្នាំ202

# សេចក្ដីសង្ខេបប្រតិបត្តិ
# អំពីក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

## ក. សាវតារគម្រោង

រាជរដ្ឋាភិបាលកម្ពុជា (RGC) តាមរយៈក្រសួងរ៉ែ និងថាមពល (MME) និងអគ្គិសនីកម្ពុជា (EDC) កំពុងអនុវត្តគម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅកម្ពុជា (CSET) ដោយទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីធនាគារពិភពលោក (WB) ក្រោមឥណទានរបស់សមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) ចំនួនប្រហែល 110 លានដុល្លារអាមេរិក សម្រាប់ដំណាក់កាលទី 1 នៃកម្មវិធីវិធីសាស្ត្រពហុដំណាក់កាល (MPA)។ MPA គាំទ្រដល់ការធ្វើអន្តរកាលរបស់កម្ពុជាឱ្យក្លាយជាប្រព័ន្ធថាមពលដែលអាចទុកចិត្តបាន បញ្ចេញកាបូនទាប និងធន់នឹងអាកាសធាតុ តាមរយៈការពង្រឹងហេដ្ឋារចនាសម្ព័ន្ធបណ្ដាញអគ្គិសនី ដោយធ្វើសមាហរណកម្មថាមពលកកើតឡើងវិញ និងការស្តុកទុក ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពថាមពលនៅក្នុងវិស័យឧស្សាហកម្មតាមរយៈការផ្តល់ហិរញ្ញប្បទានសម្បទាន។

គោលបំណងអភិវឌ្ឍន៍គម្រោង (PDO) គឺដើម្បីពង្រឹងភាពអាចទុកចិត្តបាន និងសមត្ថភាពនៃហេដ្ឋារចនាសម្ព័ន្ធបណ្ដាញអគ្គិសនីជាតិ និងកែលម្អប្រសិទ្ធភាពថាមពលនៅផ្នែកតម្រូវការ។ គម្រោងនេះរួមចំណែកដោយផ្ទាល់ដល់ផែនការអភិវឌ្ឍន៍វិស័យថាមពលរបស់ប្រទេសកម្ពុជា (ឆ្នាំ2024) និងគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល (NEEP ឆ្នាំ2023) និងគាំទ្រដល់គោលដៅរបស់រដ្ឋាភិបាលក្នុងការសម្រេចបានចំណែកថាមពលកកើតឡើងវិញចំនួន 70 ភាគរយឱ្យបានត្រឹមឆ្នាំ2030។

## ខ. ដំណាក់កាលនៃគម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅកម្ពុជា (CSET)

គម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅកម្ពុជា (CSET) នឹងអនុវត្តដោយបែងចែកជាពីរដំណាក់កាលបន្តបន្ទាប់គ្នា ស្របតាមការត្រៀមខ្លួនរួចរាល់ផ្នែកបច្ចេកទេស អត្ថិភាពហិរញ្ញប្បទាន និងសមត្ថភាពស្ថាប័ន៖

- **ដំណាក់កាលទី 1 (ឆ្នាំ2026–2030)** ផ្តោតលើការវិនិយោគស្នូលលើការពង្រឹងបណ្ដាញអគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធអំណោយផល រួមមាន៖

- ការសាងសង់ខ្សែអាកាសបញ្ជូនអគ្គិសនី 230 kV (Overhead Transmission Line) និងអនុស្ថានីយនៅទីរាជធានីភ្នំពេញ និងខេត្តកណ្ដាល។
- ការដំឡើងប្រព័ន្ធផ្ទុកថាមពលអាគុយ (BESS) ទំហំ 100–150 MWh នៅ អនុស្ថានីយអគ្គិសនីត្បូងឃ្មុំ។
- ការពង្រីក និងការធ្វើទំនើបកម្មបណ្ដាញចែកចាយអគ្គិសនី រួមទាំងប្រព័ន្ធ AMI និង
- ការបង្កើតបន្ទាត់ឥណទានប្រសិទ្ធភាពថាមពលនៅក្នុងវិស័យឧស្សាហកម្មតាមរយៈធនាគារសហគ្រាសធុនតូច និង មធ្យមកម្ពុជា និងធនាគារ FTB។

ដំណាក់កាលនេះក៏គ្របដណ្ដប់ទៅលើការពង្រឹងស្ថាប័នក្នុងដំណាក់កាលដំបូង និងការកសាងសមត្ថភាពនៅក្រោមសមាសធាតុទី 3 ផងដែរ។

- **ដំណាក់កាលទី 2 (ក្រោយឆ្នាំ2030)** នឹងអនុវត្តដោយផ្អែកលើសមិទ្ធផលសម្រេចបាននៅក្នុងដំណាក់កាលទី 1 ដោយពង្រីកសមត្ថភាពបណ្ដាញអគ្គិសនី និងការតភ្ជាប់ប្រព័ន្ធបណ្ដាញអគ្គិសនី បង្កើនហិរញ្ញប្បទានសម្រាប់បង្កើនប្រសិទ្ធភាពថាមពលនៅក្នុងវិស័យឧស្សាហកម្ម និងការគាំទ្រដល់ការវិនិយោគបន្ថែមទៀតលើថាមពលកកើតឡើងវិញ និងយានយន្តអគ្គិសនី (e-mobility)។

ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) នេះគ្របដណ្ដប់តែលើសកម្មភាពដែលនៅក្រោមដំណាក់កាលទី 1 ប៉ុណ្ណោះ ហើយនឹងត្រូវពិនិត្យមើលឡើងវិញ និងធ្វើបច្ចុប្បន្នភាពមុនពេលធ្វើការវាយតម្លៃទៅលើដំណាក់កាលទី 2 ដើម្បីឆ្លុះបញ្ចាំងអំពីសកម្មភាព បច្ចេកវិទ្យា ឬតំបន់ភូមិសាស្ត្រថ្មីណាមួយ ព្រមទាំងដើម្បីធានាឱ្យបាននូវអនុលោមភាពជាបន្តបន្ទាប់ស្របតាមលក្ខខណ្ឌតម្រូវរបស់ធនាគារពិភពលោក និងលក្ខខណ្ឌតម្រូវការជាតិ។

## គ. គោលបំណង និងវិសាលភាពនៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF)

ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ធានាថាសកម្មភាពនៃគម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅកម្ពុជា (CSET) ត្រូវបានធ្វើផែនការ និងអនុវត្តស្របតាមស្តង់ដារបរិស្ថាន និងសង្គម (ESS) របស់ធនាគារពិភពលោក និងច្បាប់នៃប្រទេសកម្ពុជាដែលពាក់ព័ន្ធ។ ក្របខណ្ឌនេះក៏ផ្ដល់ការណែនាំសម្រាប់ការត្រួតពិនិត្យ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនៃគម្រោងពីដើមដល់ចប់ផងដែរ។

ដោយហេតុថាគម្រោងនេះ មានកម្រិតហានិភ័យកម្រិតបង្គួរដែលពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការធ្វើលទ្ធកម្មដីធ្លី ភាពរសើបនៃជីវៈចម្រុះ និងជនជាតិដើមភាគតិចនៅក្នុងតំបន់គោលដៅ

ទើបក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) លើកឡើងអំពីនីតិវិធីសម្រាប់ការត្រួតពិនិត្យអនុគម្រោង ការរៀបចំឧបករណ៍ការពារសុវត្ថិភាព ការទទួលខុសត្រូវរបស់ស្ថាប័ន និងការរៀបចំថវិកាសម្រាប់ការកាត់បន្ថយ និងការកសាងសមត្ថភាព។

ដោយហេតុថា ទីតាំងអនុគម្រោងជាក់លាក់មួយចំនួន និងការរចនាលម្អិតមិនទាន់បានរៀបចំបញ្ចប់ជាស្ថាពរនៅពេលធ្វើការវាយតម្លៃ ទើបក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) នេះផ្តល់នូវក្របខណ្ឌដែលមានរចនាសម្ព័ន្ធ ដើម្បីផ្តល់ការណែនាំដល់ការកំណត់រក ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម នៅពេលដែលព័ត៌មានលម្អិតអំពីគម្រោង។ ដើម្បីសម្រួលឱ្យមានការអនុវត្តការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ប្រកបដោយសង្គតិភាព និងប្រសិទ្ធភាព ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) បានដាក់បញ្ចូលទម្រង់គំរូស្តង់ដារ នីតិវិធី និងការណែនាំអំពីវិធីសាស្រ្តជាឧបសម្ព័ន្ធ។

## ឃ. សមាសធាតុគម្រោងដោយមានការគ្របដណ្តប់ទីតាំងភូមិសាស្ត្រ

ដំណាក់កាលទី 1 នៃគម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅកម្ពុជា (CSET) នឹងផ្តល់អាទិភាពដល់ការវិនិយោគជាយុទ្ធសាស្រ្តដែលបង្កើនភាពអាចជឿទុកចិត្ត ប្រសិទ្ធភាព និងភាពធន់នៃប្រព័ន្ធថាមពលរបស់កម្ពុជា និងផ្តល់ការគាំទ្រដល់ការធ្វើអន្តរកាលឆ្ពោះទៅរកថាមពលស្អាត។ ដំណាក់កាលនេះ មានសមាសធាតុសំខាន់ៗចំនួនបីដែលអនុវត្តដោយអគ្គិសនីកម្ពុជា និងក្រសួងរ៉ែ និងថាមពល។

តារាងទី 1 អនុសមាសធាតុដោយមានការគ្របដណ្តប់ទីតាំងភូមិសាស្រ្ត

| សមាសធាតុ/<br>អនុសមាសធាតុគម្រោង | បរិយាយសង្ខេប | ការគ្របដណ្តប់ទីតាំង<br>ភូមិសាស្ត្រ |
|---|---|---|
| **សមាសធាតុទី 1៖ ការពង្រឹងបណ្តាញប្រព័ន្ធអគ្គិសនីដើម្បីការធ្វើអន្តរកាលថាមពល (អនុវត្តដោយអគ្គិសនីកម្ពុជា)** | | |
| SC 1.1៖ ការពង្រឹងបណ្តាញប្រព័ន្ធអគ្គិសនីសម្រាប់ការសម្របសម្រួល | ការសាងសង់ខ្សែអាកាសបញ្ជូនអគ្គិសនី 230 kV (Double-Circuit Overhead Transmission Line (OHT) (សរុបប្រហែល 15 គីឡូម៉ែត្រ) និងអនុស្ថានីយថ្មី | ទីរាជធានីភ្នំពេញ និងខេត្តកណ្តាល |

| សមាសធាតុ/ អនុសមាសធាតុគម្រោង | បរិយាយសង្ខេប | ការគ្របដណ្តប់ទីតាំងភូមិសាស្ត្រ |
| --- | --- | --- |
| | ដែលពាក់ព័ន្ធនៅតំបន់អរិយក្សត្រ និងជ្រោយចង្វារទី III ជាមួយនឹងការពង្រីក Line Bay នៅអនុស្ថានីយអគ្គិសនីល្វាឯម ដើម្បីគាំទ្រដល់កំណើនតម្រូវការ និងការនាំចូលថាមពលអគ្គិសនីពីប្រទេសឡាវ។ | |
| SC 1.2៖ ការវិនិយោគលើប្រព័ន្ធផ្ទុកថាមពលអាគុយ (BESS) | ការដំឡើង 100–150 MWh BESS នៅអនុស្ថានីយអគ្គិសនីត្បូងឃ្មុំ (TKM) ដើម្បីបង្កើនស្ថិរភាពអគ្គិសនីដែលអាចឱ្យធ្វើការផ្លាស់ប្តូរបន្ទុកចរន្ត (Load Shifting) និងបង្កើនប្រសិទ្ធភាពប្រតិបត្តិការ។ | ខេត្តត្បូងឃ្មុំ |
| SC 1.3៖ ការពង្រីក និងការពង្រឹងបណ្តាញចែកចាយ | ការពង្រីក និងការស្តារឡើងវិញនូវបណ្តាញ បង្គោល និងត្រង់ស្វូ (Transformers) តង់ស្យុងមធ្យម និងទាប (MV/LV) ដើម្បីបង្កើនភាពជឿទុកចិត្តនៃសេវាកម្ម កាត់បន្ថយការខាតបង់ផ្នែកបច្ចេកទេស និងតភ្ជាប់ទៅកាន់ភូមិដែលនៅសេសសល់ដែលមិនទាន់បានតភ្ជាប់អគ្គិសនីប្រើប្រាស់នៅក្នុងតំបន់អាជ្ញាបណ្ណអគ្គិសនីកម្ពុជា និងសេវាករឯកជន។ ការដំឡើងកុងទ័រ (Meters) និងប្រព័ន្ធ AMI។ | ចំនួនប្រហែលជារហូតដល់ 15 ខេត្តនៅទូទាំងប្រទេសកម្ពុជា (តំបន់ជនបទ និងតំបន់ជុំវិញទីក្រុង) |
| **សមាសធាតុទី 2៖ ប្រសិទ្ធភាពថាមពលនៅក្នុងវិស័យឧស្សាហកម្ម និងការពង្រឹងស្ថាប័ន (អនុវត្តដោយក្រសួងរ៉ែ និងថាមពល)** | | |

| សមាសធាតុ/ អនុសមាសធាតុគម្រោង | បរិយាយសង្ខេប | ការគ្របដណ្តប់ទីតាំងភូមិសាស្ត្រ |
|---|---|---|
| SC 2.1៖ បន្ទាត់ឥណទានសម្រាប់បច្ចេកវិទ្យាប្រសិទ្ធភាពថាមពល | ការផ្តល់ឥណទានសម្បទានដល់សហគ្រាសឧស្សាហកម្មតាមរយៈធនាគារសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា (ធនាគារគោលនយោបាយ) និងធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB) (គ្រឹះស្ថានហិរញ្ញវត្ថុដែលចូលរួមក្នុងគម្រោង) ដើម្បីគាំទ្រដល់ការទទួលប្រើប្រាស់នូវបច្ចេកវិទ្យា និងដំណើរការដែលមានប្រសិទ្ធភាពថាមពល។ | ទូទាំងប្រទេស |
| **សមាសធាតុទី 3៖ ការគាំទ្រដល់ការអនុវត្ត និងជំនួយបច្ចេកទេស** | | |
| SC 3.1 ផ្តល់ការគាំទ្រការអនុវត្តដល់ក្រសួងរ៉ែ និងថាមពល | ផ្តល់ការគាំទ្រដល់អង្គភាពគ្រប់គ្រងគម្រោង (PMU) របស់ក្រសួងរ៉ែ និងថាមពលសម្រាប់គ្រប់គ្រងបន្ទាត់ឥណទាន ដើម្បីប្រសិទ្ធភាពថាមពលឧស្សាហកម្ម រួមទាំងការបណ្តុះបណ្តាល ប្រព័ន្ធពិនិត្យតាមដាន និងការអនុលោមតាម ESF។ | ថ្នាក់ជាតិ |
| SC 3.2៖ ផ្តល់ការគាំទ្រការអនុវត្តដល់អគ្គិសនីកម្ពុជា | ផ្តល់ការគាំទ្រដល់អង្គភាពគ្រប់គ្រងគម្រោង (PMU) របស់អគ្គិសនីកម្ពុជា សម្រាប់ការងារលទ្ធកម្ម ការត្រួតពិនិត្យវិស្វកម្ម ការគ្រប់គ្រងបរិស្ថាន និងសង្គម និងការរាយការណ៍អំពីគម្រោង។ | ថ្នាក់ជាតិ |

## ខ. ក្របខណ្ឌច្បាប់ និងគោលនយោបាយពាក់ព័ន្ធ

ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ត្រូវរៀបចំបង្កើតឡើងដើម្បីអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់កម្ពុជា ក៏ដូចជាក្របខណ្ឌបរិស្ថាន និងសង្គម (ESF) របស់ធនាគារពិភពលោក។ លិខិតុបករណ៍ជាតិសំខាន់ៗ រួមមានជាអាទិ៍៖

- **ក្រមបរិស្ថាន និងធនធានធម្មជាតិ (ឆ្នាំ2023)៖** ច្បាប់បរិស្ថានចម្បង ដែលបង្រួបបង្រួម និងជំនួសឱ្យច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឆ្នាំ1996។ ក្រមនេះបង្កើតគោលការណ៍ថ្មីៗសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ការគ្រប់គ្រងការបំពុល ការអភិរក្សជីវៈចម្រុះ និងការរួមបញ្ចូលការប្រែប្រួលអាកាសធាតុផងដែរ។
- **ប្រកាសលេខ 021 ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ (ឆ្នាំ2000)** និងអនុក្រឹត្យ និងគោលការណ៍ណែនាំរបស់ក្រសួងដែលបានចេញជាបន្តបន្ទាប់ដោយក្រសួងបរិស្ថាន ដែលកំណត់អំពីដំណើរការសម្រាប់ការវាយតម្លៃ ការពិនិត្យមើល និងការអនុម័តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA)។
- **ច្បាប់ស្តីពីអគ្គិសនី (ឆ្នាំ2001)** ដែលគ្រប់គ្រងលើការផលិត ការបញ្ជូន និងការចែកចាយអគ្គិសនី។
- **ច្បាប់ភូមិបាល (ឆ្នាំ2001) និងច្បាប់ស្តីពីអស្សាមិករណ៍ (ឆ្នាំ2001)** ដែលគ្រប់គ្រងលើការកាន់កាប់ដីធ្លី សំណង និងដោះស្រាយផលប៉ះពាល់។
- **ច្បាប់ស្តីពីការងារ (ឆ្នាំ1997) បញ្ញត្តិស្តីពីសុវត្ថិភាព និងសុខភាពការងារ និងបទប្បញ្ញត្តិស្តីពីសុវត្ថិភាពសំណង់។**
- **ច្បាប់ស្តីពីកិច្ចការពារ និងការលើកកម្ពស់សិទ្ធិជនជាតិដើមភាគតិច (ឆ្នាំ2009)** ដែលធានាសិទ្ធិក្នុងការពិគ្រោះយោបល់ កិច្ចការពារវប្បធម៌ និងការប្រើប្រាស់ដីធ្លីសម្រាប់សហគមន៍ជនជាតិដើមភាគតិច។

គម្រោងនេះក៏ប្រកាន់ខ្ជាប់នូវ**ស្តង់ដារបរិស្ថាន និងសង្គមទាំងដប់របស់ធនាគារពិភពលោក (ESSs)** និង**គោលការណ៍ណែនាំស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាព (EHSGs)** ដែលពាក់ព័ន្ធផងដែរ។ ក្នុងករណីមានខ្លឹមសារខុសគ្នារវាងច្បាប់ជាតិ និងលក្ខខណ្ឌតម្រូវរបស់ធនាគារពិភពលោក នោះស្តង់ដារពាក់ព័ន្ធដែលមានលក្ខណៈសមស្របទៅនឹងបរិបទមូលដ្ឋានច្រើនជាង នឹងត្រូវយកមកអនុវត្ត (ឧទាហរណ៍ ការបរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត គឺមិនត្រូវបានយកមកអនុវត្តនៅក្រោមគម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅកម្ពុជា (CSET) នោះទេ ទោះបីជាត្រូវបានអនុញ្ញាតក្រោម ESS5 របស់ធនាគារពិភពលោកក៏ដោយ)។

## ច. លក្ខខណ្ឌមូលដ្ឋានផ្នែកបរិស្ថាន និងសង្គម

គម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅកម្ពុជា (CSET) នឹងគាំទ្រដល់សកម្មភាពអនុគម្រោងនៅក្នុងខេត្តមួយចំនួននៅទូទាំងប្រទេសកម្ពុជា រួមមាន រាជធានីភ្នំពេញ ខេត្តកណ្តាល ត្បូងឃ្មុំ និងខេត្តដទៃទៀត ដែលបង្ហាញអំពីលក្ខខណ្ឌអេកូឡូស៊ី និងសេដ្ឋកិច្ចសង្គមចម្រុះ។ បរិស្ថានរូបវន្តនៅក្នុងខេត្តទាំងនេះមានតាំងពីតំបន់ទំនាបលិចទឹក និងតំបន់ទំនាបកសិកម្មនៅក្នុងអាងទន្លេមេគង្គ-ទន្លេសាបរហូតដល់ប្រព័ន្ធទន្លេ ខ្ពង់រាប និងតំបន់ទេសភាពព្រៃឈើនៅតំបន់ភាគឦសាននៃប្រទេស។

យោងតាមទស្សនៈបរិស្ថាន ទីតាំងគម្រោងមានភាពរសើបក្នុងកម្រិតខុសៗគ្នាទៅតាមទីតាំង និងតំបន់ជិតទៅជម្រកធម្មជាតិ។ ខ្សែបញ្ជូនអគ្គិសនី និងអនុស្ថានីយអគ្គិសនី ក្រោមអនុសមាសធាតុ 1.1 មានទីតាំងស្ថិតនៅក្នុងតំបន់ទំនាបលិចទឹកនៃរាជធានីភ្នំពេញ និងខេត្តកណ្តាល ជាទីតាំងដែលមានផ្ទៃដីភាគច្រើនជាដីកសិកម្ម និងត្រូវបានកែប្រែការប្រើប្រាស់រួចរាល់ដោយមនុស្ស។ លទ្ធផលនៃការត្រួតពិនិត្យបង្ហាញឱ្យឃើញថាគន្លងខ្សែបញ្ជូនជាតិ (Transmission Alignment) និងអនុស្ថានីយអគ្គិសនី ដែលបានស្នើឡើង ជាទូទៅ គឺមានទីតាំងនៅខាងក្រៅតំបន់ការពារថ្នាក់ជាតិ។ ទោះជាយ៉ាងណាក៏ដោយ ផ្នែកខ្លះនៃគន្លងខ្សែបញ្ជូនអាកាស ២៣០ គ.វ៉ ដែលបានស្នើឡើងអាចនឹងប៉ះពាល់ដល់តំបន់ជាយភាគខាងត្បូងនៃតំបន់ជីវចម្រុះសំខាន់ៗបឹងវាលសំណាប (KBA) និងតំបន់សត្វស្លាបសំខាន់ៗ។

ប្រព័ន្ធផ្ទុកថាមពលអាគុយ (BESS) នៅក្រោមអនុសមាសធាតុ 1.2 នឹងត្រូវដំឡើងនៅក្នុងអនុស្ថានីយអគ្គិសនីត្បូងឃ្មុំ (TKM) ដែលមានស្រាប់ ដែលមានទីតាំងស្ថិតនៅខេត្តត្បូងឃ្មុំនៅលើដីដែលជាកម្មសិទ្ធិរបស់អគ្គិសនីកម្ពុជា ហើយមិនស្ថិតនៅក្នុង ឬជិតតំបន់ការពារ ឬតំបន់អេកូឡូស៊ីដែលងាយរងគ្រោះណាមួយឡើយ។ ហេតុដូច្នេះ ភាពងាយរងគ្រោះផ្នែកបរិស្ថាននៅទីតាំងគោលដៅនេះត្រូវបានចាត់ទុកថាមានកម្រិតទាប។

សម្រាប់ការពង្រីក និងពង្រឹងបណ្តាញចែកចាយនៅក្រោមអនុសមាសធាតុ 1.3 សកម្មភាពនានានឹងអនុវត្តក្នុងបណ្តាខេត្តជាច្រើនតាមរយៈអគ្គិសនីកម្ពុជា។ ការងារភាគច្រើននឹងធ្វើឡើងនៅក្នុងបរិវេណចំណីផ្លូវ និងតំបន់រងការរំខានបច្ចុប្បន្ន។ ទោះជាយ៉ាងណាក៏ដោយ ទីតាំងជនបទមួយចំនួនអាចមានតំបន់វាលទំនាបលិចទឹក និងជម្រកនៅតាមមាត់ទន្លេដែលមានសារៈសំខាន់ផ្នែកអេកូឡូស៊ី ដែលអាចទាមទារឱ្យមានការត្រួតពិនិត្យ និងអនុវត្តវិធានការសម្រាលនៅតាមទីតាំងជាក់លាក់មួយ

ចំនួនដើម្បីបញ្ចៀសកុំឱ្យមានការរំខានដល់ប្រព័ន្ធអេកូឡូស៊ីដែលងាយរងគ្រោះ។ ការដំឡើង AMI នឹងត្រូវអនុវត្តនៅក្នុងបរិវេណនៃតំបន់ដែលបានជ្រើសរើសនៅរាជធានីភ្នំពេញ និងខេត្តកណ្តាល។

យោងតាមទស្សនៈសង្គម ខេត្តអនុវត្តគម្រោង រួមមាន ទាំងតំបន់ទីក្រុងដែលមានចំនួនប្រជាជនរស់នៅច្រើន និងសហគមន៍ជនបទដែលមានប្រជាជនរស់នៅរាយប៉ាយ។ នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល ខ្សែបញ្ជូនអគ្គិសនី (Transmission-Line) និងអនុស្ថានីយអគ្គិសនី អាចបង្កផលប៉ះពាល់ដល់ការចេញចូល សេវាប្រើប្រាស់ ឬចរាចរណ៍នៅជិតតំបន់សាងសង់ជាបណ្តោះអាសន្ន។ នៅក្នុងខេត្តជនបទមួយចំនួន ការធ្វើលទ្ធកម្មដីធ្លីខ្នាតទ្រង់ទ្រាយតូច និងការផ្លាស់ទីតាំងសកម្មភាពសេដ្ឋកិច្ចបណ្តោះអាសន្ន ឬតិចតួច អាចកើតឡើងសម្រាប់ការងារសាងសង់ បង្គោលអគ្គិសនី ឬអនុស្ថានីយអគ្គិសនី ដែលត្រូវដោះស្រាយស្របតាម ESS5 (ការធ្វើលទ្ធកម្មដីធ្លី និងការដោះស្រាយផលប៉ះពាល់)។

ជនជាតិដើមភាគតិចមានវត្តមានភាគច្រើននៅក្នុងខេត្តត្បូងឃ្មុំ ក្រចេះ មណ្ឌលគីរី និងកំពង់ឆ្នាំង ជាទីដែលពួកគេរក្សាបាននូវវប្បធម៌ និងប្រពៃណីប្រើប្រាស់ដីធ្លីពិសេសខុសៗគ្នា។ ការចូលរួមរបស់សហគមន៍ទាំងនេះនឹងអនុវត្តតាមដំណើរការពិគ្រោះយោបល់សមស្របតាមវប្បធម៌ ដោយស្របតាមស្តង់ដារបរិស្ថាន និងសង្គម ផ្នែកទី 7 របស់ធនាគារពិភពលោក (ESS7) (ជនជាតិដើមភាគតិច) ដើម្បីធានាឱ្យបាននូវបរិយាបន្ន និងការគោរពសិទ្ធិប្រពៃណីរបស់ពួកគេ។

សកម្មភាពរបស់អនុគម្រោងមួយចំនួនអាចអនុវត្តនៅតាមទីតាំងដែលជិតនឹងទីតាំងដែលមានសារៈសំខាន់ផ្នែកវប្បធម៌ជាតិ ដោយតម្រូវឱ្យអនុវត្តប្រកាន់ខ្ជាប់តាមស្តង់ដារបរិស្ថាន និងសង្គមផ្នែកទី 7 របស់ធនាគារពិភពលោក (ESS8) (បេតិកភណ្ឌវប្បធម៌)។

ការទទួលបានអគ្គិសនីប្រើប្រាស់ និងសេវាមូលដ្ឋាន ដូចជា ទឹក និងអនាម័យ មានភាពខុសគ្នាយ៉ាងទូលំទូលាយនៅទូទាំងតំបន់គម្រោង។ ខេត្តជនបទ និងខេត្តដាច់ស្រយាល ដូចជា ខេត្តក្រចេះ ពោធិ៍សាត់ និងព្រៃវែង នៅតែមានគម្លាតក្នុងការទទួលបានអគ្គិសនីប្រើប្រាស់ និងហេដ្ឋារចនាសម្ព័ន្ធមានកម្រិត ដែលនេះបញ្ជាក់អំពីការរួមចំណែករបស់គម្រោងក្នុងការលើកកម្ពស់សមធម៌ថាមពលអគ្គិសនី និងភាពជឿជាក់នៃសេវាកម្ម។

## ឆ. ហានិភ័យ និងហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលរំពឹងទុក

សកម្មភាពគម្រោងមួយចំនួននៅក្រោមគម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅកម្ពុជា (CSET) អាចបណ្តាលឱ្យមានហានិភ័យបរិស្ថាន និង/ឬសង្គម ប្រសិនបើមិនមានការគ្រប់គ្រងឱ្យបានត្រឹមត្រូវទេនោះ។ ហានិភ័យទាំងនេះមានទំហំខុសៗគ្នាទៅតាមសមាសធាតុ និងទីតាំងជាពិសេស នៅតាមទីតាំងដែលពាក់ព័ន្ធនឹងប្រព័ន្ធអេកូឡូស៊ីងាយរងគ្រោះ តំបន់ទីក្រុងដែលចំនួនមានប្រជាជនរស់នៅច្រើន ឬសហគមន៍ជនជាតិដើមភាគតិច។ ដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ និងការវាយតម្លៃបឋម

- សមាសធាតុទី 1 (EDC)៖ ហានិភ័យកម្រិតមធ្យមទៅកម្រិតបង្គួរ។ ការសាងសង់ខ្សែបញ្ជូនអគ្គិសនី និងអនុស្ថានីយអគ្គិសនី អាចបណ្តាលឱ្យមានការកាប់ឆ្ការុក្ខជាតិនៅក្នុងតំបន់មូលដ្ឋានការហូរច្រោះដី ការបង្កើតកាកសំណល់ សំឡេងរំខាន និងការរំខានដល់ប្រជាជននៅក្បែរទីតាំងនោះ ឬចរាចរណ៍នៅក្នុងតំបន់ទីក្រុង និងតំបន់នៅជុំវិញទីក្រុង។ បង្គោលអគ្គិសនីមួយចំនួនតូច មានទីតាំងប្រសព្វ ឬជាប់នឹងតំបន់ដីសើមបឹងវាលសំណាប KBA ដែលទាមទារឱ្យមានវិធានការសម្រាលផលប៉ះពាលដល់ជីវចម្រុះដោយស្របតាមស្តង់ដារ ESS6។ ការធ្វើលទ្ធកម្មដីធ្លីតិចតួចរហូតដល់មធ្យម ត្រូវបានរំពឹងថានឹងកើតឡើងសម្រាប់ដីអនុស្ថានីយអគ្គិសនីថ្មី ក៏ដូចជា ការធ្វើលទ្ធកម្មដីធ្លី សម្រាប់ទីតាំងគន្លងខ្សែបញ្ជូន និងបង្គោលអគ្គិសនីនៃខ្សែបញ្ជូនអាកាស យោងតាមស្តង់ដារ ESS5។ សុខភាព និងសុវត្ថិភាពសហគមន៍ និងកម្មករនិយោជិត ជាពិសេស សម្រាប់តំបន់ជនបទសម្រាប់ការពង្រីកបណ្តាញចែកចាយ ការគ្រប់គ្រងកម្លាំងពលកម្ម និងការគ្រប់គ្រងសម្ភារគ្រោះថ្នាក់ (ឧទាហរណ៍ ពាក់ព័ន្ធនឹងប្រតិបត្តិការ BESS ការផ្លាស់ប្តូរត្រង់ស្វូ) គឺជាចំណុចអាទិភាពសម្រាប់គ្រប់គ្រងសំខាន់ៗ

- សមាសធាតុទី 2 (MME)៖ ហានិភ័យកម្រិតទាបទៅកម្រិតមធ្យម។ បន្ទាត់ឥណទាន សម្រាប់ប្រសិទ្ធភាពថាមពលនៅក្នុងវិស័យឧស្សាហកម្មពាក់ព័ន្ធនឹងហានិភ័យបរិស្ថាន និងសង្គមនៅផ្នែកលំហូរខាងក្រោម (Downstream) ដែលមានទំនាក់ទៅនឹងប្រតិបត្តិការរបស់ភាគីខ្ចីបន្ត។ ចំណុចនេះ រួមមានជាអាទិ៍ ប្រសិទ្ធភាពធនធាន សុខភាព និងសុវត្ថិភាពការងារ និងការគ្រប់គ្រងទឹកកង្វក់ និងកាកសំណល់រឹង ដែលកិច្ចការទាំងអស់នេះត្រូវគ្រប់គ្រងតាមរយៈប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) ដែលបង្កើតឡើងសម្រាប់ធនាគារដែលចូលរួមក្នុងគម្រោង។

- សមាសធាតុទី 3 (EDC និង MME)៖ ហានិភ័យទាប។ សកម្មភាពនានាភាគច្រើនរួមមាន ជំនួយបច្ចេកទេស ការបណ្តុះបណ្តាល និងការគាំទ្រដល់ការគ្រប់គ្រងគម្រោង ដែលមានហានិភ័យ និងផលប៉ះពាល់បរិស្ថាន ឬសង្គមដោយផ្ទាល់ក្នុងកម្រិតតិចតួច។

តារាងទី 2 សេចក្តីសង្ខេបអំពីកម្រិតហានិភ័យបែងចែកតាមអនុសមាសធាតុ

| **សមាសធាតុ/អនុសមាសធាតុគម្រោង** | **ហានិភ័យបរិស្ថាន** | **ហានិភ័យសង្គម** |
|---|---|---|
| **សមាសធាតុទី 1៖ ការពង្រឹងបណ្តាញអគ្គិសនីសម្រាប់ការធ្វើអន្តរកាលថាមពល (អនុវត្តដោយ EDC)** | | |
| SC 1.1៖ ការពង្រឹងបណ្តាញអគ្គិសនី | បង្គួរ | បង្គួរ |
| SC 1.2៖ ការវិនិយោគលើប្រព័ន្ធស្តុកទុកថាមពល អាគុយ (BESS) | ទាបទៅមធ្យម | ទាបទៅមធ្យម |
| SC 1.3៖ ការពង្រីក និងការពង្រឹងបណ្តាញចែកចាយ | មធ្យមទៅបង្គួរ | ទាបទៅមធ្យម |
| **សមាសធាតុទី 2៖ ប្រសិទ្ធភាពថាមពលនៅក្នុងវិស័យឧស្សាហកម្ម និងការពង្រឹងស្ថាប័ន (អនុវត្តដោយក្រសួងរ៉ែ និងថាមពល)** | | |
| SC 2.1៖ បន្ទាត់ឥណទានសម្រាប់បច្ចេកវិទ្យាលើកកម្ពស់ប្រសិទ្ធភាពថាមពល | ទាបទៅមធ្យម | ទាបទៅមធ្យម |
| **សមាសធាតុទី 3៖ ការគាំទ្រដល់ការអនុវត្ត និងជំនួយបច្ចេកទេស** | | |
| SC 3.1 – ផ្តល់ការគាំទ្រការអនុវត្តដល់ក្រសួងរ៉ែ និងថាមពល | ទាប | ទាប |
| SC 3.2 – ផ្តល់ការគាំទ្រការអនុវត្តដល់អគ្គិសនីកម្ពុជា | ទាប | ទាប |

## ៥. វិធានការកាត់បន្ថយ និងមធ្យោបាយការពារសុវត្ថិភាពសង្គមបរិស្ថាន

ដើម្បីធានាថាហានិភ័យបរិស្ថាន និងសង្គម (E&S) ត្រូវបានកំណត់រកឃើញ កាត់បន្ថយ និងពិនិត្យតាមដានបានត្រឹមត្រូវ ស្របតាមក្របខណ្ឌច្បាប់របស់ប្រទេសកម្ពុជា និងក្របខណ្ឌបរិស្ថាន និងសង្គម (ESF) របស់ធនាគារពិភពលោក អនុគម្រោង និងសកម្មភាពទាំងអស់ដែលនៅក្រោម

គម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅកម្ពុជា (CSET) នឹងត្រូវឆ្លងកាត់ដំណើរការនៃការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមដែលមានរចនាសម្ព័ន្ធ។ វិធីសាស្ត្រនេះ អនុវត្តតាមឋានានុក្រមសម្រាលហានិភ័យដូចតទៅ៖ ការបញ្ចៀស ការកាត់បន្ថយឱ្យនៅកម្រិតអប្បបរមា ការសម្រាល/ការផ្តល់សំណង និងការបង្កើនផលជះវិជ្ជមាន។ នីតិវិធីសម្រាប់ការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម (E&S) រួមមាន ការត្រួតពិនិត្យ ការវាយតម្លៃ ការពិនិត្យឡើងវិញ ការអនុម័ត ការអនុវត្ត និងការពិនិត្យជាប្រព័ន្ធទៅលើអនុគម្រោងនៅគ្រប់សមាសធាតុពាក់ព័ន្ធទាំងអស់។ ជំហានទាំងនេះមានផ្តល់ជូននៅក្នុងតារាងខាងក្រោម៖

តារាងទី 3៖ ជំហានសម្រាប់ដំណើរការនៃការគ្រប់គ្រងហានិភ័យ
និងផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម

| **ដំណើរការ** | **ពេលវេលាសម្រាប់ធ្វើការត្រួតពិនិត្យ** | **អង្គភាព/បុគ្គលទទួលខុសត្រូវ** | **ធនធាន/កញ្ចប់ឯកសារ** |
|---|---|---|---|
| **ជំហានទី 1៖ ការត្រួតពិនិត្យបរិស្ថាន និងសង្គម (E&S)** | | | |
| ការត្រួតពិនិត្យលក្ខខណ្ឌពេញសិទ្ធិ | ការធ្វើផែនការបឋម និងការជ្រើសរើសទីតាំង | អគ្គិសនីកម្ពុជា ក្រសួងរ៉ែ និងថាមពល និង FIs | • ឧបសម្ព័ន្ធ 1៖ បញ្ជីអាជីវកម្មដែលត្រូវហាមឃាត់ |
| ការត្រួតពិនិត្យហានិភ័យ និងផលប៉ះពាល់ | ក្នុងអំឡុងពេលនៃដំណាក់កាលរៀបចំអនុវត្តសកម្មភាព | អង្គភាពគ្រប់គ្រងគម្រោង (PMU) របស់អគ្គិសនីកម្ពុជា និងក្រសួងរ៉ែ និងថាមពល ដោយមានការគាំទ្រពីទីប្រឹក្សា E&S | • ឧបសម្ព័ន្ធ 2៖ ទម្រង់ត្រួតពិនិត្យ ហានិភ័យ និងផលប៉ះពាល់ |

| ដំណើរការ | ពេលវេលា សម្រាប់ធ្វើការ ត្រួតពិនិត្យ | អង្គភាព/បុគ្គល ទទួលខុសត្រូវ | ធនធាន/កញ្ចប់ឯកសារ |
|---|---|---|---|
| **ជំហានទី 2៖ ការរៀបចំបង្កើតមធ្យោបាយគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម ការអនុម័ត និងការអនុវត្ត** | | | |
| ការរៀបចំឯកសារ E&S មុន ពេលចាប់ផ្តើមសកម្មភាព ការអនុម័ត និង ការអនុវត្ត | នៅពេលដែល ឧបករណ៍ និង ឯកសារគ្រប់គ្រង E&S ត្រូវបាន បញ្ជាក់រួចរាល់ | អង្គភាព គ្រប់គ្រង គម្រោង (PMU) របស់ អគ្គិសនីកម្ពុជា និងក្រសួងរ៉ែ និងថាមពល ដោយមានការ គាំទ្រពីទី ប្រឹក្សា/ ក្រុមហ៊ុនប្រឹក្សា E&S | • ឧបសម្ព័ន្ធ 4៖ លក្ខខណ្ឌយោង ESIA<br>• ឧបសម្ព័ន្ធ 5៖ ទម្រង់គំរូ ESMP<br>• ឧបសម្ព័ន្ធ 6៖ ទម្រង់គំរូ ESMS<br>• RAP/ARAP ដូចមាន កំណត់នៅក្នុង RPF<br>• IPP ដូចមានកំណត់នៅក្នុង IPPF<br>• LMP<br>• ផែនការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) ដែលមាន យន្តការដោះស្រាយបណ្តឹងតវ៉ា (GRM) |
| **ជំហានទី 3៖ ការត្រួតពិនិត្យ និងការរាយការណ៍** | | | |
| ការពិនិត្យតាមដាន និងរាយការណ៍ | ក្នុងអំឡុងពេល អនុវត្ត អនុសមាសធាតុ/ សកម្មភាព | អង្គភាព គ្រប់គ្រង គម្រោង (PMU) របស់ អគ្គិសនីកម្ពុជា និងក្រសួងរ៉ែ និងថាមពល ដោយមានការ | • នីតិវិធីពិនិត្យតាមដានផ្ទៃក្នុង និងខាងក្រៅ និងរបាយការណ៍ប្រចាំឆមាសដោយប្រើប្រាស់គំរូពិនិត្យតាមដាន និងរបាយការណ៍ E&S (ឧបសម្ព័ន្ធទី 10) |

| ដំណើរការ | ពេលវេលា សម្រាប់ធ្វើការត្រួតពិនិត្យ | អង្គភាព/បុគ្គលទទួលខុសត្រូវ | ធនធាន/កញ្ចប់ឯកសារ |
|---|---|---|---|
| | | គាំទ្រពីទីប្រឹក្សា E&S | |

## លក្ខខណ្ឌតម្រូវការឧបករណ៍ការពារសុវត្ថិភាព

- ហានិភ័យកម្រិតទាបៈ មិនតម្រូវឱ្យមានឯកសារ E&S លម្អិតណាមួយក្រៅពីការអនុវត្តក្រមអនុវត្តបរិស្ថាន និងសង្គម (ESCOPs) ឡើយ។
- ហានិភ័យកម្រិតមធ្យមៈ តម្រូវឱ្យមានផែនការជាក់លាក់តាមកន្លែង ឬផែនការជាក់លាក់ដោយផ្អែកលើលទ្ធផលនៃដំណើរការត្រួតពិនិត្យហានិភ័យ និងផលប៉ះពាល់។ ផែនការទាំងនេះនឹងដោះស្រាយហានិភ័យ និងផលប៉ះពាល់បណ្ដោះអាសន្ន ទ្រង់ទ្រាយតូច ជាក់លាក់តាមកន្លែង និងអាចគ្រប់គ្រងបាន។
- ហានិភ័យកម្រិតបង្គួរៈ តម្រូវឱ្យមាន ESMPs ឬ ESIA, RAP/ARAP ជាក់លាក់តាមទីតាំង និងផែនការបន្ថែម ដូចជា LMP ឬផែនការសុវត្ថិភាពអគ្គិភ័យ ផែនការគ្រប់គ្រងអាគុយ (ឧទាហរណ៍សម្រាប់ BESS ឬអនុស្ថានីយ)។
- ហានិភ័យកម្រិតខ្ពស់ៈ ការពិចារណាឡើងវិញអំពីការរចនា និងទីតាំងនៃសកម្មភាពអនុគម្រោងដោយកាត់បន្ថយកម្រិតហានិភ័យមកត្រឹមកម្រិតបង្គួរ។

## ឈ. ការរៀបចំស្ថាប័នសម្រាប់ការអនុវត្តក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF)

គម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តភាពនៅកម្ពុជា (CSET) នឹងអនុវត្តដោយអគ្គិសនីកម្ពុជា និងក្រសួងរ៉ែ និងថាមពល ដោយអគ្គិសនីកម្ពុជា ជាស្ថាប័នដឹកនាំសមាសធាតុទី 1៖ ការពង្រឹងបណ្ដាញអគ្គិសនីសម្រាប់អន្តរកាលថាមពល ហើយក្រសួងរ៉ែ និងថាមពល នឹងធ្វើការត្រួតពិនិត្យសមាសធាតុទី 2៖ ប្រសិទ្ធភាពថាមពលនៅក្នុងវិស័យឧស្សាហកម្ម និងការពង្រឹងស្ថាប័ន។ ស្ថាប័នទាំងពីរនឹងត្រូវទទួលខុសត្រូវចំពោះអនុសមាសធាតុពាក់ព័ន្ធនៃសមាសធាតុទី 3៖ ការគាំទ្រការអនុវត្ត និងជំនួយបច្ចេកទេស ដែលក្នុងនោះរួមទាំងការកសាងសមត្ថភាព ការអនុវត្តវិធានការការពារសុវត្ថិភាព និងការគាំទ្រការគ្រប់គ្រងគម្រោង។

ក្រសួងរ៉ែ និងថាមពល ក្នុងនាមជាអាជ្ញាធរបង្កើតគោលនយោបាយជាតិស្តីពីថាមពល និងជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល បានបង្កើតអង្គភាពគ្រប់គ្រងគម្រោង (PMU) ទទួលបន្ទុកដែលមានអ្នកឯកទេសផ្នែកប្រសិទ្ធភាពថាមពល លទ្ធកម្ម ការការពារសុវត្ថិភាពបរិស្ថាន និងសង្គម ហិរញ្ញវត្ថុ និងប្រព័ន្ធព័ត៌មានគ្រប់គ្រង។ PMU ត្រួតពិនិត្យការផ្តល់ហិរញ្ញប្បទានសម្បទានតាមរយៈអន្តរការីហិរញ្ញវត្ថុ និងជំនួយបច្ចេកទេស ស្របតាមយុទ្ធសាស្ត្រថាមពលស្អាតរបស់កម្ពុជា។ សមត្ថភាពរបស់ PMU ក្នុងការគ្រប់គ្រង និងពិនិត្យតាមដានការអនុលោមតាមផ្នែក E&S នឹងត្រូវពង្រឹងតាមរយៈការជ្រើសរើសទីប្រឹក្សាស្តង់ដារបរិស្ថានក្រៅម៉ោងមួយរូប និងទីប្រឹក្សាសង្គមមួយរូប។

អគ្គិសនីកម្ពុជា ជាគ្រឹះស្ថានសាធារណៈមានកំណត់របស់រដ្ឋ ស្ថិតក្រោមការគ្រប់គ្រងរួមដោយក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) គឺជាស្ថាប័នទទួលខុសត្រូវអនុវត្តហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មពាក់ព័ន្ធនឹងបណ្តាញអគ្គិសនី។ អង្គភាពគ្រប់គ្រងគម្រោង (PMU) ស្ថិតក្រោមអគ្គិសនីកម្ពុជា ដែលដឹកនាំដោយអគ្គនាយកអគ្គិសនីកម្ពុជា មានការគាំទ្រពីនាយកដ្ឋានផ្សេងៗគ្នា រួមទាំងការិយាល័យគ្រប់គ្រងគម្រោង (PMO) និងក្រុមជំនាញឯកទេសនៅក្នុងប្រតិបត្តិការបច្ចេកទេស លទ្ធកម្ម ហិរញ្ញប្បទានឥណទាន និងការគ្រប់គ្រងបរិស្ថាន និងសង្គម (SEPRO)។ អង្គភាពគ្រប់គ្រងគម្រោង (PMU) នឹងពង្រឹងការអនុលោមតាមរបស់ខ្លួនស្របតាម E&S ដោយជ្រើសរើសទីប្រឹក្សាស្តង់ដារបរិស្ថានមួយរូប និងទីប្រឹក្សាស្តង់ដារសង្គមមួយរូបឱ្យចូលរួមផ្តល់ការគាំទ្រដល់ប្រតិបត្តិការ និងការងារគ្រប់គ្រងប្រចាំថ្ងៃ។

ការងារគ្រប់គ្រងគម្រោង គឺត្រូវបានត្រួតពិនិត្យដោយគណៈកម្មាធិការដឹកនាំគម្រោង (PSC) ដែលមានតំណាងមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ក្រសួងរ៉ែ និងថាមពល អគ្គិសនីកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា (EAC) ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) ធនាគារសហគ្រាសធុនតូច និងមធ្យមនៃកម្ពុជា និងធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB) ដោយធនាគារពិភពលោកនឹងចូលរួមជាអ្នកសង្កេតការណ៍។ គណៈកម្មាធិការដឹកនាំគម្រោង (PSC) ធានាសម្របសម្រួលរវាងអន្តរស្ថាប័ន ការអនុលោមតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ការអនុម័តផែនការការងារ និងថវិកាប្រចាំឆ្នាំ និងការអនុវត្តប្រកបដោយតម្លាភាពនូវរាល់សមាសធាតុគម្រោងទាំងអស់។

## ៣. ការអភិវឌ្ឍសមត្ថភាព

ការវាយតម្លៃតម្រូវការសមត្ថភាព ត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលរៀបចំគម្រោង ដើម្បីធ្វើការវាយតម្លៃទៅលើការត្រៀមលក្ខណៈស្ថាប័នរបស់ស្ថាប័នអនុវត្ត រួមមាន ក្រសួងរ៉ែ និងថាមពល អគ្គិសនីកម្ពុជា និងធនាគារចូលរួម (ធនាគារសហគ្រាសធុនតូច និងមធ្យម និងធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB) ដើម្បីគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម (E&S) ព្រមទាំងដើម្បីធានាឱ្យបាននូវការអនុលោមតាមលក្ខខណ្ឌតម្រូវនៃក្របខណ្ឌបរិស្ថាន និងសង្គម (ESF) របស់ធនាគារពិភពលោក។ ការវាយតម្លៃនេះបានបង្ហាញអំពីកម្រិតសមត្ថភាពខុសៗគ្នានៅក្នុងចំណោមស្ថាប័នទាំងនេះ ដោយបានរៀបចំបង្កើតផែនការកសាងសមត្ថភាពដែលកែតម្រូវទៅតាមតម្រូវការ។

ផែនការកសាងសមត្ថភាព ដែលមានម៉ូឌុលបណ្តុះបណ្តាលទូទៅ បច្ចេកទេស និងឯកទេសមួយចំនួន ត្រូវបានដាក់បញ្ចូលយ៉ាងពេញលេញទៅក្នុងក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) របស់គម្រោង ដើម្បីធ្វើយ៉ាងណាធានាថាស្ថាប័នអនុវត្តទាំងអស់ត្រូវបានបំពាក់បំប៉នសមត្ថភាពដើម្បីគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមស្របតាមច្បាប់ជាតិ និងស្តង់ដាររបស់ធនាគារពិភពលោកនៅពេញមួយវដ្តនៃរយៈពេលគម្រោងពីដើមដល់ចប់។

## ង. ការចូលរួមរបស់ភាគីពាក់ព័ន្ធ

គម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តភាពនៅកម្ពុជា (CSET) នេះ លើកកម្ពស់ឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធប្រកបដោយបរិយាបន្ន និងអត្ថន័យនៅគ្រប់ដំណាក់កាលទាំងអស់នៃគម្រោង ដោយផ្តោតលើតម្លាភាព គណនេយ្យភាព និងលទ្ធភាពចូលរួម។ ផែនការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) ត្រូវបានរៀបចំបង្កើតឡើង ដើម្បីណែនាំអំពីការផ្សព្វផ្សាយបង្ហាញព័ត៌មានគម្រោង និងធានាឱ្យមានការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំង ក្រុមងាយរងគ្រោះដែលប្រឈមនឹងមិនទទួលបានអត្ថប្រយោជន៍ពីគម្រោង។

ក្នុងអំឡុងពេលរៀបចំគម្រោង អគ្គិសនីកម្ពុជា និងក្រសួងរ៉ែ និងថាមពល បានរៀបចំ កិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធសំខាន់ៗរួមមានអាជ្ញាធរមូលដ្ឋាន អគ្គិសនីខេត្តពាក់ពន្ធ័, សេវាករឯកជន និងសហគមន៍ភូមិនៅក្នុងតំបន់គោលដៅគម្រោងនៅទូទាំងខេត្តក្រចេះ ស្ទឹងត្រែង ពោធិ៍សាត់ តាកែវ ព្រៃវែង និងកណ្តាល។ ការពិគ្រោះយោបល់ទាំងនេះ បានផ្តល់ធាតុចូលដល់ការរចនាគម្រោង ជាពិសេស សម្រាប់អគ្គិសនីភាវូបនីយកម្មនៅតំបន់ជនបទ។ ការផ្សព្វផ្សាយជាសា

ធារណៈអំពីឯកសារសំខាន់ៗអំពីបរិស្ថាន និងសង្គម (E&S) រួមទាំង ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF), ESCP, SEP, ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RPF) និងក្របខណ្ឌគោលផែនការជនជាតិដើមភាគតិច (IPPF) នឹងបង្ហោះផ្សព្វផ្សាយនៅលើគេហទំព័ររបស់អគ្គិសនីកម្ពុជា និងគេហទំព័ររបស់ក្រសួងរ៉ែ និងថាមពល ដោយមានសេចក្តីសង្ខេបជាភាសាខ្មែរដើម្បីងាយស្រួលអាន។ ឯកសារទាំងនេះនឹងមានបង្ហោះផ្សព្វផ្សាយជូនយ៉ាងតិច 14 ថ្ងៃមុនកិច្ចប្រជុំពិគ្រោះយោបល់ ហើយមតិស្ថាបនាពីភាគីពាក់ព័ន្ធនឹងបញ្ចូលទៅក្នុងកំណែឯកសារស្ថាពរ។

ផែនការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) លើកឡើងអំពីការទទួលខុសត្រូវក្នុងការអញ្ជើញឱ្យមានការចូលរួមរបស់ភាគីពាក់ព័ន្ធ ជាពិសេស អង្គភាពគ្រប់គ្រងគម្រោង (PMU) នៅអគ្គិសនីកម្ពុជា និងអង្គភាពគ្រប់គ្រងគម្រោង (PMU) នៅក្រសួងរ៉ែ និងថាមពល ហើយពណ៌នាអំពីយន្តការសម្រាប់ការដាក់បណ្តឹងតវ៉ា/បណ្តឹងសាទុក្ខ មតិត្រលប់ និងការទំនាក់ទំនងជាបន្តបន្ទាប់។ ការពិគ្រោះយោបល់ដែលបានគ្រោងសម្រាប់អនុសមាសធាតុនីមួយៗ មានរៀបរាប់លម្អិតទៅតាមកម្រិត (ថ្នាក់ជាតិ ខេត្ត ស្រុក/ឃុំ) រួមទាំង អ្នកចូលរួមគោលដៅ និងពេលវេលាកំណត់។

នៅក្នុងអំឡុងពេលអនុវត្ត ការចូលរួម និងការបង្ហាញព័ត៌មានជាបន្តរបស់ភាគីពាក់ព័ន្ធ នឹងរក្សាឱ្យបន្តអនុវត្ត។ អគ្គិសនីកម្ពុជា និងក្រសួងរ៉ែ និងថាមពល នឹងផ្សព្វផ្សាយព័ត៌មានបច្ចុប្បន្នភាពអំពីគម្រោង និងឯកសារបរិស្ថាន និងសង្គមជាក់លាក់តាមទីតាំង (ឧ. ESIA, ESMP, ESMS) តាមរយៈគេហទំព័រផ្លូវការ ប្រព័ន្ធបណ្តាញសង្គម និងទីតាំងរូបវន្តក្បែរទីតាំងគម្រោង។ ឯកសារទាំងនេះនឹងមានផ្សព្វផ្សាយយ៉ាងតិច 14 ថ្ងៃមុនការពិគ្រោះយោបល់ ហើយកិច្ចប្រជុំទាំងនេះនឹងធ្វើឡើងជាភាសាក្នុងតំបន់ ដើម្បីធានាឱ្យបាននូវការយល់ដឹង និងបរិយាបន្ន។ របាយការណ៍ពិនិត្យតាមដាន និងព័ត៌មានបច្ចុប្បន្នភាពអំពីវឌ្ឍនភាពគម្រោង ក៏នឹងផ្សព្វផ្សាយជាសាធារណៈពេញមួយមួយវដ្តរយៈពេលនៃគម្រោងពីដើមដល់ចប់ផងដែរ។

## ៥. យន្តការដោះស្រាយបណ្តឹងតវ៉ា (GRM)

គម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តភាពនៅកម្ពុជា (CSET) នឹងបង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ា ដ៏រឹងមាំមួយដើម្បីធានាថា បុគ្គល កម្មករនិយោជិត និងភាគីពាក់ព័ន្ធផ្សេងទៀតដែលរងផលប៉ះពាល់ដោយគម្រោង អាចលើកឡើងអំពីក្តីកង្វល់ពាក់ព័ន្ធនឹងសមិទ្ធកម្មផ្នែកបរិស្ថាន និងសង្គម រួមទាំងការធ្វើលទ្ធកម្មដីធ្លី បញ្ហាកម្លាំងពលកម្ម ផលប៉ះពាល់ពីការសាងសង់ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ/ការបៀតបៀនផ្លូវភេទ (SEA/SH) និងបញ្ហាច្រើនទៀត។ យន្តការដោះ

ស្រាយបណ្តឹងតវ៉ា អាចចូលប្រើប្រាស់បាន រក្សាការសម្ងាត់ និងមានការឆ្លើយតប ដោយមាននីតិវិធី និងគ្រោងពេលដែលបានកំណត់យ៉ាងច្បាស់លាស់។

សម្រាប់សមាសធាតុទី 1 ដែលអនុវត្តដោយអគ្គិសនីកម្ពុជា បណ្តាញសំខាន់ចំនួនពីរនៅដំណាក់កាល់ទី 1 នឹងត្រូវដាក់ឱ្យអនុវត្ត ដូចជាបណ្តាញសហគមន៍/អាជ្ញាធរ ដែលបណ្តឹងតវ៉ាអាចលើកឡើងដោយរាយការណ៍ជូនតាមរយៈមេភូមិ/មេឃុំ ឬក្រុមប្រឹក្សាឃុំ និងស្វែងរកដំណោះស្រាយនៅកម្រិតអ្នកទទួលការ ដែលបណ្តឹងតវ៉ាដែលពាក់ព័ន្ធនឹងកម្មករនិយោជិតអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ជូនអ្នកទទួលការ ឬអ្នកគ្រប់គ្រងការដ្ឋានតាមរយៈប្រអប់ពាក្យបណ្តឹង ឬបុគ្គលប្រចាំការនៅការដ្ឋាន បន្ទាប់មក បណ្តឹងតវ៉ាទាំងនោះនឹងត្រូវពិនិត្យមើល និងដោះស្រាយដោយការិយាល័យសង្គម បរិស្ថាន និងទំនាក់ទំនងសាធារណៈ (SEPRO) របស់អគ្គិសនីកម្ពុជា។ ពាក្យបណ្តឹងដែលមិនទាន់អាចដោះស្រាយ នឹងបញ្ជូនទៅកាន់រដ្ឋបាលស្រុកដើម្បីស្នើសុំដំណោះស្រាយ និងរាយការណ៍ទៅកាន់អង្គភាពគ្រប់គ្រងគម្រោងនៃអគ្គិសនីកម្ពុជា (EDC PMU) ជាដំណាក់កាលទី 2 និងគណកម្មការដោះស្រាយបណ្តឹងតវ៉ាខេត្ត ជាដំណាក់កាលទី 3 ហើយប្រសិនបើចាំបាច់ បញ្ជូនទៅដោះស្រាយតាមប្រព័ន្ធតុលាការ ជាដំណាក់កាលទី 4។ PER&L នៅក្រោម PMU រក្សាបញ្ជីកំណត់ហេតុបណ្តឹងតវ៉ា ពិនិត្យតាមដានវឌ្ឍនភាព និងរាយការណ៍លទ្ធផលជូនធនាគារពិភពលោក ដែលជាផ្នែកមួយនៃរបាយការណ៍សមិទ្ធកម្ម E&S ជាទៀងទាត់។

សម្រាប់សមាសធាតុទី 2 ដែលដឹកនាំដោយក្រសួងរ៉ែ និងថាមពល បណ្តឹងទាក់ទងនឹងសហគ្រាសឧស្សាហកម្ម (IEs) ជាដំបូង ត្រូវដោះស្រាយតាមរយៈយន្តការដោះស្រាយបណ្តឹងតវ៉ាផ្ទៃក្នុងរបស់ធនាគារគោលនយោបាយ (Policy Bank) ជាមុនសិន (ឧ. ធនាគារសហគ្រាសធុនតូច និង មធ្យមកម្ពុជា) និងគ្រឹះស្ថានហិរញ្ញវត្ថុដែលចូលរួម (ឧ. ធនាគារ FTB) ដោយនឹងត្រូវបញ្ជូនបន្តទៅកាន់ PMU របស់ក្រសួងរ៉ែ និងថាមពល និងតុលាការប្រសិនបើចាំបាច់។ បុគ្គលទំនាក់ទំនង E&S ពី PMU របស់ក្រសួងរ៉ែ និងថាមពល នឹងធ្វើការតាមដាន និងរាយការណ៍អំពីពាក្យបណ្តឹងដែលនៅសេសសល់ជូនគណៈកម្មាធិការដឹកនាំគម្រោង និងធនាគារពិភពលោក តាមការតម្រូវ តាមរយៈយន្តការពិនិត្យតាមដាន និងរាយការណ៍។

បណ្តាញជាច្រើន រួមទាំង ការដាក់ដោយផ្ទាល់ តាមទូរសព្ទ សារ SMS អ៊ីមែល និងដោយអនាមិកមានសម្រាប់ប្រើប្រាស់។ យន្តការដោះស្រាយបណ្តឹងតវ៉ា បញ្ហាការងារពិសេសត្រូវបានបញ្ចូលនៅក្រោមកម្មវិធី LMP របស់គម្រោង ហើយពាក្យបណ្តឹង SEA/SH ត្រូវដោះស្រាយតាមពិធីសារផ្តោតលើជនរងគ្រោះ និងយន្តការបញ្ជូន ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។

## ៥. ការពិនិត្យតាមដាន និងការរាយការណ៍

គម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តភាពនៅកម្ពុជា (CSET) ដាក់បញ្ចូលក្របខណ្ឌពិនិត្យតាមដាន និងរាយការណ៍ (M&R) គ្រប់ជ្រុងជ្រោយ ដើម្បីធានាឱ្យបាននូវការអនុវត្តទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពនូវការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម (E&S) ក្នុងចំណោមសមាសធាតុគម្រោងទាំងអស់។ បុគ្គលទំនាក់ទំនង E&S ដោយមានការគាំទ្រពីទីប្រឹក្សាស្តង់ដារបរិស្ថាន និងសង្គមនៅ PMUs នឹងទទួលខុសត្រូវផ្តល់ការគាំទ្រ PMU ក្នុងអនុវត្តការងារពិនិត្យតាមដាន និងរាយការណ៍ E&S។ ការពិនិត្យតាមដានផ្ទៃក្នុងត្រូវបានធ្វើឡើងដោយស្ថាប័នអនុវត្ត ពោលគឺ អគ្គិសនីកម្ពុជា និងក្រសួងរ៉ែ និងថាមពល តាមរយៈ PMUs រៀងៗខ្លួន។ អគ្គិសនីកម្ពុជា ដោយទទួលបានការគាំទ្រពី PMO, PER&L និង SEPRO នឹងដឹកនាំការពិនិត្យតាមដានលើសមាសធាតុទី 1 ដោយផ្តោតលើការអនុលោមតាម SS-ESMPs ការត្រួតពិនិត្យទីតាំងផ្ទាល់ ការពិគ្រោះយោបល់ជាមួយសហគមន៍ ការចូលរួមរបស់ភាគីពាក់ព័ន្ធ និងការតាមដានបណ្តឹងតវ៉ា។ ក្រសួងរ៉ែ និងថាមពល ត្រួតពិនិត្យសមាសធាតុទី 2 ដោយមានការត្រួតពិនិត្យជាប្រចាំដែលនឹងធ្វើឡើងដោយធនាគារគោលនយោបាយ និងគ្រឹះស្ថានហិរញ្ញវត្ថុដែលចូលរួម ដែលជាស្ថាប័នទទួលខុសត្រូវលើការត្រួតពិនិត្យ ការពិនិត្យទីតាំងផ្ទាល់ ឯកសារ E&S និងការរាយការណ៍។

ការពិនិត្យតាមដានដោយភាគីឯករាជ្យពីខាងក្រៅដោយស្របតាម ESF របស់ធនាគារពិភពលោក នឹងត្រូវធ្វើឡើងដោយអ្នកជំនាញរបស់ភាគីទីបីដែលមានគុណវុឌ្ឍិ ដើម្បីផ្ទៀងផ្ទាត់ដោយឯករាជ្យទៅលើសមិទ្ធកម្ម E&S ជាពិសេស សម្រាប់សកម្មភាពទាំងឡាយណាដែលមានហានិភ័យខ្ពស់។ ជំនាញការទាំងនេះនឹងសម្របសម្រួលជាមួយ PMUs និងរាយការណ៍អំពីលទ្ធផលរកឃើញរបស់ពួកគេជូនក្រសួងរ៉ែ និងថាមពល និងធនាគារពិភពលោក។

អង្គភាពគ្រប់គ្រងគម្រោង (PMU) របស់អគ្គិសនីកម្ពុជា និងក្រសួងរ៉ែ និងថាមពល នឹងរៀបចំបង្កើតរបាយការណ៍ប្រចាំឆមាសដើម្បីដាក់ជូនធនាគារ។ អ្នកទទួលការ និងដៃគូអនុវត្តទាំងអស់ (រួមទាំងអគ្គិសនីកម្ពុជា អ្នកម៉ៅការសាងសង់ និងគ្រឹះស្ថានហិរញ្ញវត្ថុ) នឹងត្រូវតម្រូវឱ្យរៀបចំរបាយការណ៍បរិស្ថាន និងសង្គមប្រចាំត្រីមាស ហើយដាក់ជូនអង្គភាពគ្រប់គ្រងគម្រោង (PMU)។ ធាតុចូលទាំងនេះនឹងបញ្ចូលទៅក្នុងរបាយការណ៍ ប្រចាំត្រីមាស ឬប្រចាំឆមាសបូកសរុបរួម ដែលនឹងដាក់ជូនធនាគារពិភពលោក។

ក្នុងករណីមានឧប្បត្តិហេតុកើតឡើង អង្គភាពគ្រប់គ្រងគម្រោង (PMU) ត្រូវតែជូនដំណឹងដល់ធនាគារពិភពលោកក្នុងរយៈពេល 48 ម៉ោង និងត្រូវដាក់របាយការណ៍លម្អិតក្នុងរយៈពេល 10 ថ្ងៃធ្វើការ រួមទាំង ការវិភាគដើមចម និងផែនការសកម្មភាពកែតម្រូវ និងបង្ការ (CAPA) ផងដែរ។ អ្នកម៉ៅការសាងសង់ និងក្រុមការងារអគ្គិសនីកម្ពុជា ទាំងអស់ត្រូវរក្សាសៀវភៅបញ្ជីឧប្បត្តិហេតុជាក់លាក់តាមទីតាំង និងរាយការណ៍ភ្លាមៗអំពីហេតុការណ៍ធ្ងន់ធ្ងរ ដូចជា ករណីស្លាប់ ការបណ្តេញចេញដោយបង្ខំ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ/ការបៀតបៀនផ្លូវភេទ (SEA/SH) ឬការខូចខាតចំពោះបរិស្ថានធ្ងន់ធ្ងរ។